# សលាកប័ត្រព័ត៌មាន ៖ យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ ចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០

**ទិដ្ឋភាពរួម** ៖ សលាកប័ត្រព័ត៌មាននេះស្វែងយល់ពីការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("ប្រទេសកម្ពុជា") ក្នុងអំឡុងពេលចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ ខែមីនា ឆ្នាំ២០២០។ ក្នុងរយៈពេល ១២ ខែនេះ មានការប្រើប្រាស់យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ ("យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់") ចំនួន ១៣២ ដង។ ការអនុវត្តជាទៀងទាត់នៃយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងភាគីទី៣ បានធ្វើឲ្យប៉ះពាល់ដល់សេរីភាពបញ្ចេញមតិ និងមិនលើកទឹកចិត្តក្នុងការចូលរួមរបស់ពលរដ្ឋផងដែរ។ ផលប៉ះពាល់ដោយសារយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់នៅកម្ពុជាអាចមើលឃើញតាមរយៈករណីសិក្សាដែលបានបង្ហាញនៅខាងក្រោមនេះ។

ទិន្នន័យដែលបានបង្ហាញនៅក្នុងសលាកប័ត្រព័ត៌មាននេះ ត្រូវបានចងក្រងដោយគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ("គម្រោង") ដែលជាការអនុវត្តរួមគ្នាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមអាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ។

## ១. តើអ្វីគឺជាយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ?

យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈគឺជាបណ្តឹងដែលធ្វើឡើងដោយចេតនាដើម្បីយកមកប្រើប្រាស់បំបាក់ទឹកចិត្ត ការបំភិតបំភ័យ ការរំខាន ការបង្អាក់ ឬការបង្ហោចទ្រព្យជនជាប់ចោទ ការបំបិទសំឡេងប្រឆាំង ការរិះគន់ ឬការមិនយល់ស្របរបស់ពួកគេ។

**យុទ្ធសាស្ត្រ**= អ្វីមួយដែលបានធ្វើរួច, ដោយចេតនានិងវិធីដើម្បីឲ្យសម្រេចគោលដៅជាក់លាក់ណាមួយ

**បណ្តឹងផ្លូវច្បាប់** = វិវាទរដ្ឋប្បវេណី ឬព្រហ្មទណ្ឌដែលបញ្ជូនទៅស្ថាប័នតុលាការ

**ប្រឆាំង** = ជំទាស់នឹងអ្វីមួយ

**ការចូលរួម** = ចូលរួមចំណែកក្នុងការធ្វើអ្វីមួយ

**សាធារណៈ** = ពលរដ្ឋជាទូទៅ

តាមបែបប្រពៃណី យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ គឺជាបណ្តឹងរដ្ឋប្បវេណីដែលប្តឹងដោយភាគីទី៣។ ប៉ុន្តែនៅកម្ពុជា យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់នេះ គឺបណ្តឹងដែលធ្វើឡើងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ឬស្ថាប័នតុលាការក្នុងទម្រង់ជាទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដូចជាការកោះហៅមកសាកសួរ ឬការចោទប្រកាន់បទព្រហ្មទណ្ឌពីសំណាក់តុលាការ។

## ២. គោលបំណងនៃយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ

យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ ផ្ដោតគោលដៅជាក់លាក់ទៅលើតែសមាជិកសកម្មក្នុងសហគមន៍ដែលប្រើប្រាស់សេរីភាពបញ្ចេញមតិ។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់នេះតែងត្រូវបានស្ថាប័នមានអំណាច ដូចជារាជរដ្ឋាភិបាល ឬអ្នកមានអំណាច យកមកប្រើប្រាស់ដើម្បីបំបិទសំឡេងរិះគន់ និងបំបាក់ទឹកចិត្តដល់ប្រជាពលរដ្ឋនៅក្នុងការចូលរួមក្នុងសង្គម។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់នេះបានធ្វើឲ្យការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមធ្លាក់ចុះ ដោយសារតែការភ័យខ្លាចមានការជាប់ពន្ធនាគារ និងខ្លាចបង្កជាបន្ទុកធ្ងន់ធ្ងរផ្នែកថវិកាក្នុងការចំណាយលើសេវាច្បាប់ និងប្រាក់ពិន័យផ្សេងៗ។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់នេះត្រូវបានយកមកប្រើប្រាស់ជាយុទ្ធសាស្ត្រមួយក្នុងការបំភិតបំភ័យបុគ្គលទាំងឡាយ តួអង្គសង្គមស៊ីវិល ថ្នាក់ដឹកនាំសហគមន៍ អ្នកកាសែត អ្នកផ្សាយព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សមានការភ័យខ្លាច និងស្ងៀមស្ងាត់។

## ៣. យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈនៅកម្ពុជា




យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់នេះកើតមានជាធម្មតានៅក្នុងប្រទេសកម្ពុជា។ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រា ១៣២ ករណីដែលចាត់ទុកថាជាករណីយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ទៅលើមនុស្ស ៣៧៩នាក់ ។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ភាគច្រើនធ្វើឡើងពីសំណាក់រាជរដ្ឋាភិបាល មន្ត្រីរាជរដ្ឋាភិបាល ឬស្ថាប័នតុលាការកម្ពុជា ហើយតែងដៅមុខសញ្ញាទៅលើបុគ្គលគ្រប់ប្រភេទ។

**ចំនួនបុគ្គលដែលទទួលរងដោយសារយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ ចាប់ពីខែមេសា ២០១៩ - ខែមីនា ឆ្នាំ ២០២០**



ស្របពេលដែលការចោទពីបទព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ជាញឹកញាប់ ចំនួនករណីយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ដែលអាចឈានដល់ការផ្ដន្ទាទោស ក្នុងអំឡុងពេលជាង១២ខែមកនេះ នៅមានកម្រិតទាបនៅឡើយ។ នេះបង្ហាញឲ្យឃើញថាពីការប្រើប្រាស់យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់នេះគឺដើម្បីជាឧបករណ៍បំបាក់ទឹកចិត្ត និងរារាំងបុគ្គលផ្សេងៗពីការប្រើប្រាស់សេរីភាពមូលដ្ឋានរបស់ខ្លួនប៉ុណ្ណោះ។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់មានគោលដៅការពាររាជរដ្ឋាភិបាល និងបុគ្គលដែលមានអំណាចពីការរិះគន់ ឬជំទាស់។ ហេតុទាំងនេះនាំឲ្យមានការចាប់ខ្លួនបុគ្គលជាច្រើន និងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌទៀតសោតមានរយៈពេលយូរមិនកំណត់ ព្រមទាំងចំណាយធនធានជាច្រើន ហើយជារឿយៗករណីទាំងនោះតែងមានការឃុំខ្លួនបណ្ដោះអាសន្នជាច្រើនខែឆ្នាំ។

## ៤. ករណីសិក្សា

យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ មិនអនុវត្តតែចំពោះបុគ្គលមួយចំនួននោះទេ។ ករណីសិក្សាខាងក្រោមបង្ហាញពីយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ទៅលើមុខសញ្ញាជាច្រើននៅកម្ពុជា រួមមានអ្នកកាសែត តំណាងសហគមន៍ សមាជិកសហជីព និងសកម្មជនយុវជន ។

### លោក យាង សុជាមេត្តា និង លោក អ៊ួន ឈិន



នៅខែវិច្ឆិកា ឆ្នាំ២០១៧ អ្នកយកព័ត៌មានរបស់វិទ្យុអាស៊ីសេរីពីរនាក់គឺលោក យាង សុជាមេត្តា និងលោកអ៊ួន ឈិន ត្រូវបានចាប់ខ្លួន និងចោទពីបទប្រគល់ឲ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលធ្វើឲ្យអន្តរាយដល់ការពារជាតិនៃប្រទេសកម្ពុជា តាមមាត្រា៤៤៥ នៃក្រមព្រហ្មទណ្ឌជាមួយនឹងបទចោទទីពីរគឺការផលិតរូបភាពអាសអាភាស តាមមាត្រា៣៩ នៃច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ។ អ្នកទាំងពីរត្រូវបានដោះលែងឲ្យនៅក្រៅឃុំនៅកាលពីខែកញ្ញា ឆ្នាំ២០១៨ បន្ទាប់ពីឃុំខ្លួនបណ្ដោះអាសន្នរយៈពេលជាង៩ ខែ។

នៅក្នុងខែតុលា ឆ្នាំ២០១៩ តុលាការរាជធានីភ្នំពេញមិនបានចេញសាលក្រមទេ ដោយចេញនូវសេចក្ដីសម្រេចឲ្យមានការស៊ើបអង្កេតឡើងវិញ ដោយសារតែកង្វះភស្តុតាង។ ហេតុដូចនេះហើយ ករណីនេះត្រូវបានបន្តនីតិវិធីស៊ើបអង្កេតបន្ថែមទៀត។ បន្ទាប់មក ពួកគេបានប្ដឹងជំទាស់នឹងសេចក្ដីសម្រេចដែលបានបដិសេធដោយតុលាការរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់នេះ ធ្វើឲ្យសារព័ត៌មានដែលហ៊ានរិះគន់នៅស្ងៀមស្ងាត់បានដោយសារតែការដាក់ទោសមានកម្រិតធ្ងន់ទៅលើវិជ្ជាជីវៈប្រចាំថ្ងៃរបស់ពួកគេ និងការបន្តការគំរាមកំហែងផ្ដន្ទាទោសតាមផ្លូវតុលាការបន្ថែមទៀត។



### អ្នកស្រី ផាវ ញ៉ឹង

បណ្ដឹងបរិហាកេរ្តិ៍ឯកជនមួយត្រូវបានធ្វើឡើងចំពោះអ្នកស្រី ផាវ ញ៉ឹង ទាក់ទងនឹងសកម្មភាពពាក្យសំដីនិយាយក្នុងនាមតំណាងឲ្យសហគមន៍ជាច្រើននៅក្នុងខេត្តកោះកុង។ សហគមន៍ទាំងនោះមានជម្លោះដីធ្លីដ៏រ៉ាំរ៉ៃតាំងពីឆ្នាំ២០០៨ ជាមួយក្រុមហ៊ុនកសិកម្មស្ករអំពៅ ហេង ហ៊ុយ។ អ្នកស្រី ឆាយ រី ត្រូវជាបងស្រីលោកមេឃុំ គឺជាអ្នកដាក់ពាក្យបណ្ដឹង ប៉ុន្តែធ្វើឡើងជាឯកជនដោយចោទប្រកាន់អ្នកស្រី ផាវ ញ៉ើង ពីបទបរិហារកេរ្តិ៍ទាក់ទងនឹងនិយាយថាអ្នកស្រី ឆាយ រី បានលក់ដីសហគមន៍។ ករណីនេះកំពុងស្ថិតក្នុងនីតិវិធីតុលាការនៅឡើយ។

### សហជីព ស៊ីខៅឌូ

មនុស្សចំនួន ៤ នាក់ដែលជាសមាជិកសហជីពមូលដ្ឋាននៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (“ស៊ីខៅឌូ”) លោក សំរ៉ុង បុរី លោក ទួន ណៃឡេង លោក សែម សាម និងលោក សែម សុផល ត្រូវបានក្រុមហ៊ុន ស្យុង យិន ខេមបូឌាខូអិលធីឌី ដែលជានិយោជកប្ដឹងពាក់ព័ន្ធនឹងការចូលរួមតវ៉ានៅក្នុងរោងចក្រនៅអំឡុងខែមករា ឆ្នាំ២០២០ ដើម្បីទាមទាប្រាក់ខែដែលមិនបានបើកឲ្យកម្មករ និងដោះស្រាយទៅលើការបញ្ចប់កិច្ចសន្យាកម្មករចំនួន២០០នាក់។ កាលពីថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០២០ តុលាការខេត្តកណ្ដាលបានកោះហៅពួកគេទាំងនោះមកសាកសួរអំពីការចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ការគំរាមកំហែងធ្វើឲ្យខូចខាតនិងបង្កឲ្យមានការខូចខាតទ្រព្យសម្បត្តិដោយចេតនា។

### លោក គង់ រ៉ៃយ៉ា



កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ មួយថ្ងៃមុនថ្ងៃបុណ្យខួប៣ឆ្នាំនៃការធ្វើឃាតលោកបណ្ឌិត កែម ឡី, លោក រ៉ៃយ៉ា ជាមួយនឹងសមាជិកក្រុមគ្រួសាររបស់គាត់៣នាក់ទៀតត្រូវបានចាប់ខ្លួន ពីបទផ្សព្វផ្សាយពាណិជ្ជកម្មលក់អាវយឺតអនុស្សាវរីយ៍ដែលមានរូបភាពលោកបណ្ឌិត កែម ឡី នៅតាមបណ្ដាញសង្គមហ្វេសបុក។ សមាជិកគ្រួសារមានគ្នា៣នាក់ត្រូវបានដោះលែង ខណៈដែលលោក រ៉ៃយ៉ា ត្រូវបាននាំខ្លួនមកសាកសួរនៅតុលាការរាជធានីភ្នំពេញ ហើយបន្ទាប់មកត្រូវបានចោទពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា។ នៅទី១៩ ខែមិថុនា ឆ្នាំ២០២០ តុលាការរាជធានីភ្នំពេញបានកាត់ទោសលោក រ៉ៃយ៉ា ឲ្យជាប់ពន្ធនាគារចំនួនពីរឆ្នាំ ចំនួនដែលនៅសេសសល់ត្រូវបានព្យួរដោយសារគាត់បានអនុវត្តរួចហើយកំឡុងពេលឃុំខ្លួនបណ្ដោះអាសន្ន។

## ៥. អនុសាសន៍

ការប្រើប្រាស់យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ បានកើនឡើងជាលំដាប់នៅប្រទេសកម្ពុជាជាមួយនឹងបណ្ដឹងផ្លូវច្បាប់ជាច្រើនទៀតពីសំណាក់ភាគីទី៣ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាខ្លួនឯង។ យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់បានប៉ះពាល់ដល់សិទ្ធិមនុស្ស និងមិនលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការចូលរួមក្នុងសង្គម ព្រមទាំងនាំទៅរកវប្បធម៌ស្ងៀមស្ងាត់ដោយការកម្រិតសេរីភាពខ្លួនឯង។ ដើម្បីទប់ស្កាត់បញ្ហានេះ រាជរដ្ឋាភិបាលគួរៈ

ក. ជំរុញឲ្យមានច្បាប់ដែលហាមប្រាមយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ ប្រឆាំងនឹងការចូលរួមជាសាធារណៈ ហើយច្បាប់នោះមានចែងពីការផ្ដន្ទាទោសដល់បុគ្គល ឬស្ថាប័នដែលប្រើប្រាស់យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់។

ខ. ពិនិត្យ និងវិសោធនកម្មក្រមព្រហ្មទណ្ឌជាពិសេសបទល្មើសបរិហាកេរ្តិ៍ និងការញុះញង់ឲ្យស្របទៅតាមក្របខ័ណ្ឌច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។

គ. ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាល និងមន្ត្រីតុលាការឲ្យយល់ដឹងនិងទទួលស្គាល់ពីផលជះអំពីយុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ។

ឃ. បង្ក និងបង្កើតបរិយាកាសល្អសម្រាប់អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មានឯករាជ្យ និងសកម្មជនដែលអនុញ្ញាតឲ្យអ្នកទាំងនោះអាចធ្វើការ និងសកម្មភាពស្របច្បាប់របស់ខ្លួន៕

**ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោក ហ៊ុន ស៊ាងហាក់ អ្នកសម្របសម្រួលគម្រោងនៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ: +៨៥៥(០)១២ ៤០ ៣០ ៥០ ឬអ៊ីម៉ែល seanghak.hun@cchrcambodia.org**

## ៦. សូមអានបន្ថែម

- មជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ(អាយ.ស៊ី.អិន.អិល) ការពារសកម្មជនពីបណ្តឹងរំលោភបំពាន៖យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ(២០២០) <https://www.icnl.org/post/report/slapps-in-the-global-south-report>។
- មជ្ឈមណ្ឌលធនធានធុរកិច្ចនិងសិទ្ធិមនុស្ស, យុទ្ធសាស្ត្របណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ៖ ករណីសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ និងអនុសាសន៍សម្រាប់រដ្ឋាភិបាលធុរកិច្ច និងសង្គមស៊ីវិល (២០២០) <https://media.business-humanrights.org/media/documents/files /documents/SLAPPs_in_SEA_2020_Final_for_website.pdf>។
- អង្គការមាត្រា ១៩, របាយការណ៍សាកលនៃសេរីភាពខាងការបញ្ចេញមតិ ២០១៨/១៩: បណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ(២០១៩) <https://www.article19.org/reader/global-expression-report-2018-19/global-analysis/global-analysis-2/civic-space/vexatious-litigation-against-public-participation/>។